សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១១៥៧ អ.ក

ចុះថ្ងៃទី ០៣.តុលា.២០១៨

សាលក្រមលេខ: ០៧១ "ណ"

ចុះថ្ងៃទី ២២-០៤-២០២០

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាល បានបើកសវនាការជាសាធារណៈ នាថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២០ ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្ត កណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៥៧ អក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៨ ដែលមានជនជាប់ចោទ:

-ឈ្មោះ [redacted] ចាន់សុទ្ធា ភេទ ស្រី អាយុ ៨៨ឆ្នាំ សញ្ជាតិខ្មែរកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] មានទីកន្លែងកំណើត សង្កាត់ [redacted] ភ្នំពេញ មានអាសយដ្ឋាន [redacted] មានជ័យ រាជធានី ភ្នំពេញ ឪពុកឈ្មោះ [redacted] ឈុនបាវ (ស្លាប) ម្ដាយឈ្មោះ [redacted] គឹមសាន (ស្លាប់) ។ (ក្រៅឃុំ)

ជាប់ចោទពី បទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ កោះគ ឃុំ រកាខ្ពស់ ស្រុក ស្អាង ខេត្ត កណ្ដាល កាលពីអំឡុងឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៣៩១ និង មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា។

-លោក [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខផេង ភេទ ប្រុស អាយុ ៣៣ ឆ្នាំ មានអាសយដ្ឋាន ផ្ទះលេខ ១២៩ E0ផ្លូវលេខ ១១០ សង្កាត់ វត្តភ្នំ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

-លោក [redacted] ជាមេធាវីមានអត្តលេខ [redacted] ការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះចាន់ សុខផេង។

*អង្គហេតុនៃរឿងមានដូចតទៅ៖*

កាលពីថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឈ្មោះ ចាន់ សុខផេង បានទិញដីទំហំសរុប ជាង ៥ហិចតា (៥០ ០៨៤ ម៉ែត្រការ៉េ) តម្លៃ ២៥ ០០០ ដុល្លារអាមេរិក ដីពីរកន្លែងជាប់គ្នា ពីឈ្មោះ [redacted] ឆុន និង ឈ្មោះ [redacted] ចាន់សុទ្ធាទីតាំងស្ថិតនៅ ភូមិ កោះគ ឃុំ រកាខ្ពស់ ស្រុក ស្អាង ខេត្ត កណ្ដាល។ ឈ្មោះ [redacted] ឆុន បានធ្វើការរត់ការផ្ទេរកម្មសិទ្ធិលើដីទំហំ ២.២ ហិចតារួចរាល់ ប៉ុន្តែ ឈ្មោះ [redacted] ចាន់សុទ្ធា វិញ ចាប់តាំងពីថ្ងៃទិញដីរហូតមកដល់ឆ្នាំ ២០១៨ ឈ្មោះនេះ បានប្រើល្បិចកលបោកបញ្ឆោត រកពេលគេចវេះ មិនព្រមរត់ការផ្ទេរកម្មសិទ្ធិដីទំហំ ២,៨ ហិចតាឱ្យ ឈ្មោះ [redacted] សុខផេង នោះទេ បែរជាលក់ឱ្យអ្នកផ្សេងថែមទៀត។



Scanned with CamScanner

បានឃើញ ដីកាសម្រេចដំណោះស្រាយ លេខ ០២២ ដកដស ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០២០ ។

បានឃើញ ដីកាចាត់តាំង ចៅក្រមជំនុំជម្រះលេខ ១២៧ដកដច ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ។

## នាពេលសុខនាការ

-អានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា ឆ្លើយថាៈ កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ខ្លួន បានធ្វើកិច្ចសន្យាលក់ដីទំហំ ២,៥ ហិចតា ក្នុងតម្លៃ ១ ម៉ែត្រការ៉េ ០,៩កាក់ ស្ថិតនៅ ភូមិ កោះគរ ឃុំ រកាខ្ពស់ ស្រុក ស្អាង ខេត្ត កណ្ដាល ទៅឱ្យឈ្មោះ [redacted] សុខផេង ដោយមាន កិច្ចសន្យាទិញលក់ទិញលក់ត្រឹមត្រូវ ដោយឈ្មោះ [redacted] ចាន់សុផេង បានកក់ប្រាក់ ៨ ០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក ហើយក្នុងកិច្ចសន្យាបានចែងថា អ្នកលក់ត្រូវរត់ឯកសារ កាត់ប្លង់អោយអ្នកទិញរួចរាល់ ហើយទើបបង់លុយគ្រប់ចំនួន។ ដោយចៃដន្យខាងជលផល ស្រុកស្អាង ដោយទាមទារយកដីរបស់ខ្លួន និង អ្នកជិតខាងក្បែរនោះ ចំនួន៦០ហិកតាដោយ ប៉ះពាល់ ដីរបស់ខ្លួនទាំងអស់ ហើយក៏មានការតវ៉ារបស់ប្រជាពលរដ្ឋ។ ក្រោយមក ខាងជល ផល និង សុរិយោដីស្រុកស្អាង គំរោងតំបន់វិនិច្ឆ័យ២ បានប្រគល់ដីរបស់ខ្លួន មកឱ្យ ខ្លួនវិញ បាន ១ហិកតា និង ៧០អា។ ក្រោយពីទទួលដីនោះមកខ្លួនបានដើររកឈ្មោះ [redacted] សុខផេង មកផ្ដិតមេដៃលើអក្សរ ដើម្បីអោយសុរិយោដីចេញប្លង់ដីឱ្យឈ្មោះ [redacted] សុខផេង។ តែខ្លួនមិន បានជួបឈ្មោះ [redacted] សុខផេងនោះទេ ។ ដោយសារជីវភាពខ្លួនខ្វះខាត ទើបខ្លួន បាន យកដីនោះទៅលើកឱ្យក្រុមហ៊ុន លី វុឌ្ឍី ជ្រេនីងគ្រុប នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៨ ។ ពេល លក់បានរយៈពេលប្រហែល ១ឆ្នាំ ក៏ត្រូវឈ្មោះ ចាន់សុខផេង បានមកប្ដឹងខ្លួនពីបទ រំលោភ លើទំនុកចិត្ត ដោយផ្អែកលើកិច្ចសន្យាប្រាក់កក់នោះ។ ខ្លួនសំណូមពរអោយតុលាការជួយ លើកលែងចោទប្រកាន់លើខ្លួន ហើយខ្លួនសុំសងប្រាក់ ៨ ០០០ (ប្រាំបីពាន់)ដុល្លារអាមេរិក ដល់ភាគីអ្នកទិញវិញ។

-អានពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] សុខផេង ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៨។

-អានកិច្ចសន្យាលក់ដីផ្ដាច់ ចុះថ្ងៃទី ១០ ខែ ១១ ឆ្នាំ ២០១០ ។

-មេធាវីលោក [redacted] ប៊ុនស្រ៊ាន ការពារសិទ្ធិឱ្យដើមបណ្ដឹងសន្និដ្ឋានៈ កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឈ្មោះ [redacted] សុខផេង បានទិញដីពីរកន្លែងជាប់គ្នា ដែលមាន ទំហំសរុបជាងហិចតា ពីឈ្មោះ [redacted] ឆុន និង ឈ្មោះ [redacted] ចាន់សុទ្ធា។ ក្រោយពីបានទិញដី ខាងលើរួចមក ឈ្មោ[redacted] ឆុន បានធ្វើការផ្ទេរកម្មសិទ្ធិមកអោយឈ្មោះ [redacted] សុខផេង រួចរាល់អស់ហើយ ចំណែកឈ្មោះ [redacted] ចាន់សុទ្ធា បន្ទាប់ពីបានទទួលលុយថ្លៃទិញដីរហូត ដល់ឆ្នាំ២០១៨ ឈ្មោះនេះ ពុំបានធ្វើការផ្ទេរកម្មសិទ្ធិលើផ្ទៃដីដែលបានព្រមព្រៀងគ្នានោះ ទេ ដោយប្រើល្បិចកលបោកបញ្ឆោតរកលេស គេចវេសមិនព្រមធ្វើការផ្ទេរកម្ម សិទ្ធិដី ដែលបានព្រមព្រៀងតាមកិច្ចសន្យានោះទេ មិនតែប៉ុណ្ណោះរកលេសគេចវេស មិនព្រមធ្វើ ការផ្ទេរកម្មសិទ្ធិដី ដែលបានព្រមព្រៀងតាមកិច្ចសន្យានោះទេ មិនតែប៉ុណ្ណោះ ឈ្មោះ [redacted] ចាន់សុទ្ធា បានយកដីនេះ ទៅលក់អោយអ្នកផ្សេងថែមទៀត។

-តំណាងអយ្យការសន្និដ្ឋានៈ មានភស្តុតាង និង ពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា ពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ កោះគ ឃុំ រកាខ្ពស់ ស្រុក ស្អាង ខេត្ត កណ្ដាល កាលពីអំឡុងឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៣៩១ និង មាត្រា ៣៩២ នៃ ក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សន្និដ្ឋានៈ ក្រោយពីធ្វើការពិនិត្យឯកសារភស្តុតាង និង ស្ដាប់ការឆ្លើយបំភ្លឺជនជាប់ចោទ ឃើញថា កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ចាន់សុទ្ធា ពិតជាបានលក់ដីមួយកន្លែង ដែលមានទំហំ ២ហិច តាទៅឱ្យឈ្មោះ [redacted] ចាន់សុទ្ធា ដោយបានធ្វើកិច្ចសន្យាលក់ផ្ដាច់ចុះថ្ងៃទី ១០-១១-២០១០



Scanned with CamScanner

ភាគីអ្នកទិញបានកក់ប្រាក់ ជូនកូនក្តីខ្លួន ចំនួន ៨ ០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក ។ តាំងពីកក់រួចមកកូនក្តីរបស់ខ្លួន បានស្វែងរកអ្នកទិញដីដើម្បីធ្វើឯកសារផ្ទេរ ប៉ុន្តែអ្នកទិញគេមិនបានអនុវត្តទៅតាមកិច្ចសន្យានោះទេ។ រឿងនេះជារឿងកិច្ចសន្យាទិញលក់ ជារឿងរដ្ឋប្បវេណីសុទ្ធសាត សូមមេលោកចៅក្រមមេត្តាពិនិត្យឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **យល់ឃើញថា៖**

ក.អំពីពិរុទ្ធភាព៖

១-តាមដីកាដំណោះស្រាយលេខ ០២២ ដកដស ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០២០ បានសម្រេចបញ្ជូនសំណុំរឿងព្រហ្មទណ្ឌ និង ជនត្រូវចោទឈ្មោះ [redacted] ចាន់សុទ្ធា ទៅតុលាការជំនុំជម្រះ ពីបទ បទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ កោះគ ឃុំ រការខ្ពស់ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៣៩១ និង មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា ឆ្លើយថា: កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ខ្លួន បានធ្វើកិច្ចសន្យាលក់ដីទំហំ ២,៥ ហិចតា ក្នុងតម្លៃ ១ ម៉ែត្រការ៉េ ០,៩កាក់ ស្ថិតនៅ ភូមិ កោះគរ ឃុំ រកាខ្ពស់ ស្រុក ស្អាង ខេត្ត កណ្តាល ទៅឱ្យឈ្មោះ [redacted] សុខផេង ដោយមានកិច្ចសន្យាទិញលក់ទិញលក់ត្រឹមត្រូវ ដោយឈ្មោះ [redacted] ចាន់សុផេង បានកក់ប្រាក់ ៨ ០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក ហើយក្នុងកិច្ចសន្យាបានចែងថា អ្នកលក់ត្រូវតែឯកសារកាត់ប្លង់អោយអ្នកទិញរួចរាល់ ហើយទើបបង់លុយគ្រប់ចំនួន។ ដោយចែដន្យខាងជលផលស្រុកស្អាងដោយទាមទារយកដីរបស់ខ្លួន និង អ្នកជិតខាងក្បែរនោះ ចំនួន ៦០ហិកតា ដោយប៉ះពាល់ដីរបស់ខ្លួនទាំងអស់ ហើយក៏មានការតវ៉ារបស់ប្រជាពលរដ្ឋ។ ក្រោយមក ខាងជលផល និងសុរិយោដីស្រុកស្អាង គំរោងតំបន់វិនិច្ឆ័យ២ បានប្រគល់ដីរបស់ខ្លួនមកឱ្យខ្លួនវិញ បាន ១ហិកតា និង ៧០អា។ ក្រោយពីទទួលដីនោះមកខ្លួនបានដើររកឈ្មោះ [redacted] សុខផេង មកផ្តិតមេដៃលើអក្សរ ដើម្បីអោយសុរិយោដីចេញប្លង់ដីឱ្យឈ្មោះ [redacted] សុខផេង។ តែខ្លួន មិនបានជួបឈ្មោះ [redacted] សុខផេងនោះទេ ។ ដោយសារជីវភាពខ្លួនខ្វះខាត ទើបខ្លួនបានយកដីនោះទៅលើកឱ្យក្រុមហ៊ុន លី វុឌ្ឍី ជ្រេឌីងគ្រប នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៨ ។ ពេល លក់បានរយៈពេលប្រហែល ១ឆ្នាំ ក៏ត្រូវឈ្មោះ [redacted] សុខផេង បានមកប្តឹងខ្លួនពីបទ រំលោភលើទំនុចចិត្តដោយផ្អែកលើកិច្ចសន្យាប្រាក់កក់នោះ។ ខ្លួនសំណូមពរអោយតុលាការជួយ លើកលែងចោទប្រកាន់លើខ្លួន ហើយខ្លួនសុំសងប្រាក់ ៨ ០០០ (ប្រាំបីពាន់)ដុល្លារអាមេរិក ដល់ភាគីអ្នកទិញវិញ។

៣-តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សុខផេង ឱ្យដឹងថា: កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ខ្លួនបានទិញដី ទំហំ សរុបជាង ៥ហិចតា ជាដី ២កន្លែងជាប់គ្នា នៅភូមិ កោះគ ឃុំ រការខ្ពស់ ស្រុក ស្អាង ខេត្ត កណ្តាល ហើយឈ្មោះ [redacted] ធុន បានវត់ប្លង់ ២,២ ហិចតា អោយរួចហើយ ដោយឡែកឈ្មោះ [redacted] ចាន់សុទ្ធា ក្រោយពីទទួលប្រាក់កក់ ថ្លៃទិញដីហើយ មិនឃើញរត់ការប្លង់មកប្រគល់ឱ្យខ្លួននោះទេ។

៤-តាមកិច្ចសន្យាលក់ដីផ្តាច់ចុះថ្ងៃទី ១០ ខែ ១១ ឆ្នាំ ២០១០បញ្ជាក់ថាបានថា ឈ្មោះ [redacted] ចាន់សុទ្ធា បានលក់ដីអោយឈ្មោះ [redacted] សុខផេង ដោយភាគីអ្នកទិញបានប្រគល់ប្រាក់កក់ចំនួន ១០ ០០០ (មួយម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃទី ១០ ខែ ១១ ឆ្នាំ ២០១០ ហើយសន្យាប្រគល់ប្រាក់បង្គ្រប់នៅពេលរត់ការធ្វើប័ណ្ណកម្មសិទ្ធិដាក់ឈ្មោះ អ្នកទិញរួចរាល់ជាស្ថាពរ។

៥-តំណាងអយ្យការសន្និដ្ឋាន: មានភស្តុតាង និង ពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា ពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ កោះគ ឃុំ រការខ្ពស់ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៣៩១ និង មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៦-ជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា បានទទួលប្រាក់កក់ពីឈ្មោះ [redacted] សុខផេង រួចហើយ ដោយមានធ្វើកិច្ចសន្យាលក់ដីផ្តាច់ ដោយអោយឈ្មោះ [redacted] ចាន់សុទ្ធា រត់ការធ្វើប័ណ្ណកម្មសិទ្ធិ អោយទៅឈ្មោះ [redacted] សុខផេង នឹងប្រគល់ប្រាក់គ្រប់ចំនួន តែឈ្មោះ [redacted] ចាន់សុទ្ធា បែរជាលក់ដីនេះទៅឱ្យអ្នកផ្សេងទៅវិញ។ តាមកិច្ចសន្យាលើកដីផ្តាច់ ឈ្មោះ [redacted] ចាន់សុទ្ធា មានកាតព្វកិច្ចត្រូវបំពេញឯកសារផ្ទេរកម្មសិទ្ធ ទៅឈ្មោះ [redacted] សុខផេង។ ការដែលឈ្មោះនេះយកដីនេះទៅលក់អោយអ្នកផ្សេង ដោយពុំបានជូនដំណឹង និង ប្រគល់ប្រាក់កក់ទៅឱ្យភាគីអ្នកទិញវិញ ឬ ពុំទាន់រំលាយកិច្ចសន្យា ទិញលក់ដីតាមផ្លូវតុលាការរដ្ឋប្បវេណី គឺចេតនាទុច្ចរិត ដែលត្រូវបានក្រមព្រហ្មទណ្ឌ ចែង និង ផ្តន្ទាទោស ពីបទ រំលោភលើទំនុកចិត្ត តាម បញ្ញត្តិមាត្រា ៣៩១ និង មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និង សណ្តាប់ធ្នាប់សង្គម ដូចនេះត្រូវតែទទួលខុសត្រូវ ចំពោះមុខច្បាប់ ។

៨-មានភស្តុតាង បញ្ជាក់ពីពិរុទ្ធគ្រប់គ្រាន់លើជនជាប់ឈ្មោះ [redacted] ចាន់សុទ្ធា (មានសាវតាជាតិគ្រប់គ្រាន់ដូចខាងលើ) ពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ កោះគ ឃុំ រការខ្ពស់ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៣៩១ និង មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

ខ.អំពីសំណាងរដ្ឋប្បវេណី៖

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឈ្មោះ [redacted] សុខផេង ពុំមានចម្លើយបញ្ជាក់អំពីសំណាងរដ្ឋប្បវេណី គប្បីតុលាការពុំអាចលើកយកមកពិចារណាបានឡើយ។

**ហេតុដូច្នេះ-តុលាការ**

**សម្រេច**

១.ផ្តន្ទាទោសលើ

ក.ជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ

ពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ កោះគ ឃុំ រការខ្ពស់ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៣៩១ និង មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.ចេញដីកាចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់សុទ្ធា និង កំបាំងមុខ ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សុខផេង ទុកសិទ្ធិប្តឹងទាស់ និង ឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **តំណាងអយ្យការ** | **ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]



Scanned with CamScanner